# សហគមន៍តំបន់ការពារធម្មជាតិ សំបូរអភិវឌ្ឍន៍

## ភូមិសំបូរ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ









**ខែកក្កដា ឆ្នាំ២០២៥**

គម្រោង INRM

អនុវត្តដោយ៖

គាំទ្រដោយ៖

gef

UNDP

PEACETIME ORGANIZATION

# ចូលរួមរៀបចំការផលិតដោយ៖

**ប្រមូលទិន្នន័យ និងរៀបចំចងក្រង**

ក្រុមការងារអង្គការសុខិតកាល

**ផ្តល់ទិន្នន័យ**

គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍»

**ពិនិត្យ និងផ្តល់យោបល់**

ក្រុមការងារគម្រោងINRM

**ព័ត៌មានទំនាក់ទំនង**

info@peace-time.org

**លេខទំនាក់ទំនងសហគមន៍**

០៩៦ ៣៩១ ៨៥២៧

# ព័ត៌មានប្រជាសាស្ត្រ និងភូមិសាស្ត្រ



## សាវតារសហគមន៍

សហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» មានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃ «គូលែន-ព្រហ្មទេព» ស្ថិតនៅភូមិសំបូរ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ហើយត្រូវបានទទួលស្គាល់ជាផ្លូវការតាមរយៈប្រកាសលេខ១៧៣ប្រ.ប.ស្ថ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ពីក្រសួងបរិស្ថាន។ សហគមន៍នេះគ្របដណ្តប់លើផ្ទៃដី១០៧១ហិកតានិងមានសមាជិកសរុបចំនួន ១៧២ គ្រួសារ ឬស្មើនឹង ៨០៨ នាក់។

ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» គឺធ្វើឡើងក្នុងគោលបំណងមួយចំនួនដូចខាងក្រោម៖

- ចូលរួមថែរក្សាការពារធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ដើម្បីធានានូវការផ្គត់ផ្គង់ធនធានធម្មជាតិដល់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ឱ្យមាននិរន្តរភាពទាំងបច្ចុប្បន្ន និងសម្រាប់កូនចៅជំនាន់ក្រោយ
- ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិក្នុងតំបន់ដើម្បីរក្សាបាននូវលំនឹងធម្មជាតិ
- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការការពារ និងថែរក្សាធនធានធម្មជាតិដោយសហគមន៍មូលដ្ឋានសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សហគមន៍។

## រចនាសម្ព័ន្ធសហគមន៍

រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» មានទៅតាមលំដាប់គឺចាប់ពី ថ្នាក់ក្រុម ថ្នាក់អនុគណៈកម្មការ ថ្នាក់គណៈកម្មការសហគមន៍អមដោយទីប្រឹក្សា និងអ្នកគាំទ្រសហគមន៍(អ្នកសម្របសម្រួល)។ ហើយថ្នាក់នីមួយៗត្រូវបានកំណត់ចំនួនដូចខាងក្រោម៖

- ថ្នាក់ក្រុមមាន១១ក្រុម ហើយក្រុមនីមួយៗមានប្រធាន០១រូប និងអនុប្រធាន០១រូប
- ថ្នាក់អនុគណៈកម្មការមានចំនួន ១រូប ជាបុរស
- ថ្នាក់គណៈកម្មការមានចំនួន ០៧រូប ក្នុងនោះមានស្ត្រី០៣រូប

# ព័ត៌មានប្រជាសាស្ត្រ និងភូមិសាស្ត្រ

## ការប្រើប្រាស់ធនធានធម្មជាតិ

រាល់ការដេកហូតធនធានធម្មជាតិសម្រាប់បម្រើផលប្រយោជន៍នៅក្នុងសហគមន៍គឺត្រូវមានការឯកភាពពីសមាជិកសហគមន៍ទាំងមូល ដោយឆ្លងយោបល់ទីប្រឹក្សាសហគមន៍ និងឱ្យស្របទៅតាមផែនការគ្រប់គ្រងសហគមន៍។ ហើយការប្រមូលធនធានធម្មជាតិសម្រាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារក៏ត្រូវធ្វើឡើងដោយស្របតាមបទដ្ឋានបច្ចេកទេសនៃតំបន់ការពារធម្មជាតិ។ដោយឡែកការដេកហូតធនធានធម្មជាតិ (អនុផលព្រៃឈើ) សម្រាប់លក់ដូរគឺត្រូវសុំការអនុញ្ញាតពីគណៈកម្មការសហគមន៍តាមរយៈប្រធានក្រុម។ ចំពោះការដេកហូតឈើសំណង់ប្រើប្រាស់ជាលក្ខណៈគ្រួសារគឺត្រូវតែដាក់ពាក្យស្នើសុំទៅគណៈកម្មការសហគមន៍ក្នុងរយៈពេលពី ៣ ទៅ ៥ថ្ងៃជាមុន ដោយបញ្ជាក់ពីមូលហេតុ កាលបរិច្ឆេទ ទីតាំង ទំហំ ប្រភេទ និងចំនួនឱ្យបានច្បាស់លាស់។ ប្រជាជនក្នុងភូមិដែលមិនមែនជាសមាជិកសហគមន៍ និងអ្នកភូមិជិតខាងអាចអនុញ្ញាតឱ្យធ្វើការប្រមូលធនធានធម្មជាតិ (អនុផលព្រៃឈើ) សម្រាប់ប្រើប្រាស់ជាលក្ខណៈប្រពៃណីតែត្រូវធ្វើឡើងដោយស្របទៅតាមលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ សំបូរអភិវឌ្ឍន៍។

## អនុផលព្រៃឈើ និងរុក្ខជាតិឱសថ

ខាងក្រោមនេះគឺជាតារាងបញ្ជីឈ្មោះនៃអនុផលព្រៃឈើ និងឱសថជាច្រើនប្រភេទ ដែលមានវត្តមាននៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍»៖

| **វត្តមានអនុផលព្រៃឈើសំខាន់ៗ** | | |
|---|---|---|
| ផ្សិត | ត្នោតចោត | ជ័រចុង |
| ផ្កាចាហួយ | ស្លឹកដូងព្រះ | តាជៀងទ័ល |
| ឬស្សី | ផ្ដៅ | ទឹកឃ្មុំ |
| **វត្តមានរុក្ខជាតិឱសថសំខាន់ៗ** | | |
| មុខធ្មៀង | ក្រឧបឈ្មោល | ធ្លក |
| ផ្ចៅស្រែង | រំពុកក្រហម | ចំបក់ |
| ក្រឡិតចក | ធើមធ្នា | ត្រមេង |
| រំដេញមាស | រំពុកស | កណ្ដោល |
| ឈ្លីកពក | នាងនួន | ល្វា |
| ភ្លូបាត | មមាំង | ប្រប្រឹត |
| ដើមបង្កី | ព្រាលជ្រូក | ដើម៣០ |
| ដើមស្មៀស | ផ្លែសុក្រំ | ដើមតាលីងក្រហម |
| វល្លិ៍មៀតស | វល្លិ៍មៀតក្រហម | ដើមស្លឹកបី |

## ប្រភពចំណូលក្នុងសហគមន៍

ប្រជាជនភាគច្រើនដែលរស់នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» គឺពឹងផ្អែកលើមុខរបរសំខាន់ៗដែលមានដូចជាការធ្វើកសិកម្មចំនួនរហូតដល់ទៅ៥៨% លក់ដូរ១% ការប្រមូលអនុផលព្រៃឈើ២២% និងផ្សេងៗ(លក់កម្លាំងពលកម្ម) ចំនួន១៩%។

### ទិន្នន័យមុខរបរសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» ឆ្នាំ២០២៥




**វត្ថុមានអនុផលព្រៃឈើសំខាន់ៗដែលអាចដកហូតបានតាមរដូវកាល ឆ្នាំ២០២៥ ដោយ១៧២គ្រួសារ (១០០%)**

| ប្រភេទ | ចំនួនគ្រួសារ(១០០%) | រដូវ | បរិមាណ/១គ្រួសារ | តម្លៃ/១គ.ក |
|---|---|---|---|---|
| ផ្សិតប៉ក់ | ១០០% | មេសា ដល់ ឧសភា | ២គីឡូក្រាម | ៥០០០០៛ |
| ផ្សិតកញ្ចូរ | ៥០% | មីថុនា ដល់ កក្កដា | ៥ គីឡូក្រាម | ១៣០០០៛ |
| ផ្សិតក្ងោក | ៥០% | មីថុនា ដល់ កញ្ញា | ៣០គីឡូក្រាម | ១៥០០០៛ |
| ផ្សិតដំបូក | ១០% | មីថុនា ដល់ កក្កដា | ០.៥ គីឡូក្រាម | ២០០០០០៛ |
| ទឹកឃ្មុំ | ១០% | កុម្ភៈ ដល់ ឧសភា | ៣លីត្រ | ៦០០០០៛ |
| ត្នោតចោត | ៣០% | កក្កដា ដល់ កញ្ញា | ៣គីឡូក្រាម | ៣០០០៛ |
| ទំពាំងព្រិច | ៥០% | ឧសភា ដល់ កញ្ញា | ៥គីឡូក្រាម | ២៥០០៛ |
| ទំពាំងឫស្សីក្រៀម | ១០% | មីថុនា ដល់ សីហា | ៣គីឡូក្រាម | ៩០០០០៛ |
| ស្លឹកដូងព្រះ | ១០% | មករា ដល់ ធ្នូ | ៣គីឡូក្រាម | ៥០០០៛ |

# ព័ត៌មានសក្តានុពលទេសចរណ៍

## ទេសចរណ៍ធម្មជាតិនិងសហគមន៍

បើទោះបីជាការរៀបចំទេសចរណ៍ធម្មជាតិនៅសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» មិនទាន់មានភាពប្រសើរនៅឡើយក៏ដោយ ប៉ុន្តែសហគមន៍នេះក៏មានសក្តានុពលទេសចរណ៍ជាច្រើនកន្លែងសម្រាប់ទាក់ទាញភ្ញៀវទេសចរអាចមកលេងកំសាន្តបានផងដែរ។ សហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» អាចរៀបចំដំណើរកំសាន្តសម្រាប់ភ្ញៀវទេសចរចូលទៅបោះតង់ក្នុងព្រៃសហគមន៍ ចូលកំសាន្តក្នុងព្រៃជ្រៅមើលរុក្ខជាតិកម្រៗដូចជាផ្កាអ័រគីដេព្រៃ ផ្កាបាយដើម និងរុក្ខជាតិឱសថជាច្រើនផ្សេងទៀត។ ក្រៅពីនេះភ្ញៀវទេសចរក៏អាចចូលព្រៃទៅមើលសត្វទាស្លាបស សត្វក្ងោក និងសត្វក្រៀលផងដែរ។






# ភាពជោគជ័យរបស់សហគមន៍

សហគមន៍តាមមូលដ្ឋានក្នុងប្រទេសកម្ពុជា គឺកំពុងបង្ហាញពីគំនិតផ្តួចផ្តើមប្រកបដោយនិរន្តរភាពក្នុងការជំរុញការអភិរក្សបរិស្ថាន និងកំណើនសេដ្ឋកិច្ច។នៅខេត្តព្រះវិហារ សហគមន៍សំបូរអភិវឌ្ឍន៍ក៏មាននូវភាពជោគជ័យរបស់ខ្លួនក្នុងការងារអភិរក្សធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពប្រជាសហគមន៍។ សហគមន៍មួយនេះមានអនុផលព្រៃឈើយ៉ាងសម្បូរបែបដែលអាចជួយសម្រួលដល់ជីវភាពរបស់ប្រជាជន បានយ៉ាងច្រើនផងដែរ។ ក្រៅពីនេះសហគមន៍ក៏អាចរកចំណូលបានមួយផ្នែកទៀតតាមរយៈការរៀបចំជាកញ្ចប់ទេសចរណ៍សម្រាប់នាំ ភ្ញៀវជាតិនិងអន្តរជាតិទៅទស្សនាកំសាន្តក្នុងព្រៃ មើលផ្កាអរគីដេព្រៃ បោះតង់ និងមើលសត្វស្លាបជាច្រើនប្រភេទទៀតផង។

លើសពីនេះ ពួកគាត់រក្សាការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដាំដើមឈើឡើងវិញ និងធ្វើការល្បាតព្រៃឈើជាប្រចាំ ដើម្បីទប់ស្កាត់ការកាប់ឈើ និងការបរបាញ់ដោយខុសច្បាប់។ លោក អ៊ិត សំអឿន អ្នកដឹកនាំសហគមន៍បានចែករំលែកទស្សនៈរបស់គាត់ថា "ការការពារព្រៃឈើរបស់យើង មិនមែនគ្រាន់តែជាការអភិរក្សធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីធានាភាពបិតបេរនៃធនធានរបស់យើង តាមរយៈការប្រមូលផលព្រៃឈើប្រកបដោយទំនួលខុសត្រូវ ហើយបន្តផ្តល់ជូននូវស្រស់ស្អាតនៃព្រៃឈើដល់ភ្ញៀវទេសចរ។ យើងធានាបាននូវអត្ថប្រយោជន៍យូរអង្វែងសម្រាប់សហគមន៍របស់យើង"។

វឌ្ឍនភាពសេដ្ឋកិច្ចនៃសហគមន៍ទាំងបីនេះ គឺបានបង្ហាញឱ្យឃើញ ពីភាពជោគជ័យនៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សហគមន៍សំបូរអភិវឌ្ឍន៍ក្នុងខេត្តព្រះវិហារ ដែលមានសមាជិកចំនួន ១៧២គ្រួសារក៏អាចទទួលបានចំណូលចន្លោះពី ៧០ម៉ឺនរៀល (១៧៥ដុល្លារ) ដល់ ៨០ម៉ឺនរៀល (២០០ដុល្លារ) ក្នុងមួយខែ ក្នុង១គ្រួសារ។ ហើយប្រាក់ចំណូលសរុបក្នុងរយៈពេលបីខែ (ខែមីនា ដល់ឧសភា) ឈានដល់ចន្លោះពី ៣៦១.២០០.០០០រៀល (២០៨.០៣០ដុល្លារ) ទៅ ៩០.០០១ដុល្លារ (១០២.៣០០ ដុល្លារ) តាមរយៈការប្រមូលផលអនុផលព្រៃឈើ។

សហគមន៍ទាំងនេះបានបង្ហាញឱ្យឃើញពីថាមពលនៃនិរន្តរភាពក្នុងសកម្មភាពការងារសហគមន៍ ដែលមានទាំងការអនុវត្តប្រកបដោយនិរន្តរភាពលើការអភិរក្សអេកូឡូស៊ី និងជំរុញកំណើនសេដ្ឋកិច្ចមូលដ្ឋាន។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់គឺពិតជាអាចយកធ្វើជាគំរូសម្រាប់ទៅអនុវត្តក្នុងតំបន់ផ្សេងទៀត ហើយបង្ហាញពីរបៀបដែលគំនិតផ្តួចផ្តើមមូលដ្ឋាននេះអាចនាំឱ្យមានការផ្លាស់ប្តូរប្រកបដោយអត្ថន័យ។ នៅពេលដែលសហគមន៍ទាំងនេះបន្តការងារជាគំរូល្អដូចនេះ ពួកគាត់ក៏បានផ្តល់ឱ្យឃើញនូវចក្ខុវិស័យដ៏ជោគជ័យមួយអំពីអនាគតដែលការអភិរក្ស និងការអភិវឌ្ឍន៍បានដើរទន្ទឹមគ្នា។

## ព័ត៌មានគម្រោងដៃគូអភិវឌ្ឍសហគមន៍

តាំងពីចាប់ផ្តើមបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «សំបូរអភិវឌ្ឍន៍» ក្នុងឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០២៥ សហគមន៍បានទទួលការគាំទ្រពីគម្រោងជាច្រើនក្នុងការអនុវត្តការងារឆ្លើយតបទៅនឹងគោលបំណងនិងចក្ខុវិស័យសហគមន៍ ក្នុងកិច្ចការការពារធនធានធម្មជាតិក៏ដូចជាជួយដល់ការលើកកម្ពស់ជីវភាពសហគមន៍ជាដើម។

| ល.រ | ស្ថាប័ន | គម្រោង | វិស័យ | ឆ្នាំ |
|---|---|---|---|---|
| ០១ | អង្គការសមាគមអភិរក្សសត្វព្រៃប្រចាំកម្ពុជា | អង្គការសមាគមអភិរក្សសត្វព្រៃប្រចាំកម្ពុជា | • ការពារធនធានធម្មជាតិ<br>• ការបណ្តុះបណ្តាលគ្រប់គ្រងសហគមន៍ | ២០១២-២០២៥ |
| ០២ | អង្គការ World Vision | អង្គការ World Vision | • ការតស៊ូមតិក្នុងការការពារធនធានធម្មជាតិ<br>• លើកកម្ពស់ជីវភាពប្រជាសហគមន៍ | ២០១៥-២០២០ |
| ០៣ | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ ការអភិវឌ្ឍអន្តរជាតិ (USAID) | គម្រោងព្រៃឡង់បៃតង | • ការពារធនធានធម្មជាតិ<br>• លើកកម្ពស់ជីវភាពប្រជាសហគមន៍<br>• ការពង្រឹងសមត្ថភាពសហគមន៍ | ២០១៩-២០២៣ |
| ០៤ | ក្រសួងបរិស្ថាន | គម្រោងការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងតំបន់ទេសភាពនៃព្រៃធម្មជាតិ និងផលិតភាពធម្មជាតិនៅតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា(INRM) | • ការពារធនធានធម្មជាតិ និងការដាំស្តារ<br>• លើកកម្ពស់ជីវភាពប្រជាសហគមន៍<br>• បណ្តុះបណ្តាលការងារផ្សព្វផ្សាយពីធនធានធម្មជាតិ | ២០២៣-២០២៥ |

គម្រោង INRM
អនុវត្តដោយ៖
គាំទ្រដោយ៖

# Community Profile- Sambo Aphivath Community Protected Area

Sambo Village, Srayang Commune, Kulen District, Preah Vihear Province









**July 2025**

# Prepared by:

-

Data collection and compilation

Peacetime Organization Team

Provided information

Sambo Aphivath Community Protected Area Committee

Reviewed by

INRM Team

Contact

info@peace-time.org

Community Phone

096 391 8527

# Demographics and Historical Background




## History of the Community

The Sambo Aphivath Community Protected Area is located within the Kulen–Promtep Wildlife Sanctuary, in Sambo Village, Srayang Commune, Kulen District, Preah Vihear Province. It was officially recognized through Proclamation No. 173, dated March 28, 2012, issued by the Ministry of Environment. The community covers an area of 1,071 hectares and has a total of 172 households, equivalent to 808 people.

The establishment of the Sambo Aphivath Community Protected Area serves several objectives as follows:

- To participate in the conservation and protection of natural resources within the protected area, ensuring the sustainable supply of natural resources for the local community's use—both in the present and for future generations.
- To improve the natural resources within the area in order to maintain ecological balance.
- To participate in implementing the Royal Government's policy on the protection and conservation of natural resources by local communities, aiming to contribute to poverty reduction within the community.

## Community Structure

The management structure of the Sambo Aphivath Community Protected Area is organized in the following hierarchy: starting from the Group Level, followed by the Sub-Committee Level, then the Community Committee Level—supported by advisors and community supporters (coordinators). The number of members at each level is determined as follows:

- At the Group Level, there are 11 groups, each with 1 leader and 1 deputy leader.
- At the Sub-Committee Level, there is 1 member, who is male.
- At the Community Committee Level, there are 7 members, of which 3 are women.

# Demographics and Historical Background

## Natural Resources

Any extraction of natural resources for the benefit of the community must have the agreement of all community members, with consultation from the community advisor, and must comply with the community management plan. The collection of natural resources for household use must also follow the technical standards of the protected area.

Meanwhile, the extraction of natural resources (forest by-products) for trade must be approved by the community committee through the group leader. For extracting construction wood for household use, a request must be submitted to the community committee 3 to 5 days in advance, clearly stating the reason, harvest date, location, size, type, and quantity.

Villagers who are not members of the community, as well as those from neighboring villages, may be allowed to collect natural resources (forest by-products) for traditional use, but such activities must comply with the bylaws of the Sambo Aphivath Community Protected Area.

## Non-timber forest products and medicinal plants

The table below is a list of the names of various forest products and medicinal plants that are found in the Sambo Aphivath Community Protected Area.

| | | |
|---|---|---|
| **Presence of major non-timber forest products** | | |
| Mushroom | Toddy palm fruit | Resin |
| Curcuma parviflora | Doung Preah | Tatang Tal |
| Bamboo | Rattan | Honey |
| **Presence of major medicinal plants** | | |
| Mukh Chnieng | Krakhop Chhmaol | Thlok |
| Chhke Sreng | Rambok Krohorm | Chambak |
| Kraleit Chak | Phorm Chhma | Trameng |
| Rumdinh Meas | Rambok Sor | Kandol |
| Chleik Pok | Neang Nuon | Lvea |
| Phlubat | Mamaeng | Pra Brut |
| Daem Bongki | Preal Chruk | Daem 30 |
| Daem Spias | Phle Sukrom | Daem Taling Krahom |
| Ramiat Sor Vine | Ramiat Krahom Vine | Slek Bey Vine |

# Economic and Livelihood Information of the Community

## Sources of income in the community

The majority of the population living in the Sambo Aphivath Community Protected Area rely on key livelihoods such as agriculture, accounting for up to 58%, home-based business at 1%, collection of forest products at 22%, and other activities (such as selling labor) at 19%.




**Presence of major non-timber forest products that can be harvested seasonally in 2025 by 172 households (100%)**

| Type | HHs (100%) | Season | QTY/1HH | Price/1Kg |
|---|---|---|---|---|
| Mushroom Pak | 100% | April to May | 2 Kg | 50000 Riels |
| Mushroom Kanjo | 50% | June to July | 5 Kg | 13000 Riels |
| Mushroom Ka Ngok | 50% | June to Sept | 30 Kg | 15000 Riels |
| Mushroom Dambok | 10% | June to July | 0.5 Kg | 200000 Riels |
| Honey | 10% | Feb to May | 3 Liters | 60000 Riels |
| Toddy palm fruit | 30% | July to Sept | 3 Kg | 3000 Riels |
| Bamboo Shoot | 50% | May to Sept | 5 Kg | 2500 Riels |
| Dry Bamboo shoot | 10% | June to August | 3 Kg | 90000 Riels |
| Doung Preah Leaves | 10% | Jan to Dec | 3 Kg | 5000 Riels |

# Tourism potential information

## Ecotourism and Community

Although the organization of ecotourism in the Sambo Aphivath Community Protected Area is not yet well developed, the community still has significant tourism potential, with many sites that can attract visitors for recreation. The Sambo Aphivath Community Protected Area can organize recreational trips for tourists, such as camping in the community forest, exploring the deep forest to observe various plants like wild orchids, rice-flower trees, and many medicinal plants. In addition, tourists can also go into the forest to see wildlife such as peafowls, pheasants, and squirrels.






# Success Story

Cambodia's local community is demonstrating the power of sustainable initiatives in driving environmental conservation and economic growth. In Preah Vihear, Sambo Akphivoat Community is sustaining itself through the harvesting of non-timber forest products while offering guided nature packages that allow visitors to explore the forest, marvel at vibrant orchid flowers, and observe local bird species. Additionally, they maintain a strong commitment to reforestation and conduct regular forest patrols to deter illegal logging and poaching.

Mr. Ith Sameourn, a community leader, shared his perspective, saying, "Protecting our forest is not just about preserving nature; it's about securing our future. By responsibly harvesting what the forest provides and sharing its beauty with visitors, we ensure long-term benefits for our community."

The economic progress of this community highlights the success of sustainable resource management. Sambo Aphivat in Preah Vihear sees 172 households earning between 700,000 riels ($175) and 800,000 riels ($200) per month, with total income over three months (March–May) reaching between 361,200,000 riels ($90,300) and 412,800,000 riels ($102,300) through harvesting non-timber forest products.

The community demonstrates that sustainable practices can drive both ecological preservation and economic growth. Their efforts serve as a model for other regions, highlighting how grassroots initiatives can lead to meaningful change. As these communities continue their work, they offer a promising vision of a future where conservation and development go hand in hand.

## Information on community development partner projects

Since the establishment of the Sambo Aphivath Community Protected Area in 2012 up to 2025, the community has received support from various projects in implementing activities that respond to the community's goals and vision, including natural resource protection as well as initiatives that help improve the livelihoods of the community.

| No | Institution | Project | Field | Year |
|---|---|---|---|---|
| 01 | Wildlife Conservation Society | WCS's Project | • Natural resource protection<br>• Community management training | 2012-2025 |
| 02 | World Vision | World Vision's Project | • Advocacy on natural resource protection<br>• Improving community livelihoods | 2015-2020 |
| 03 | United States Agency for International Development (USAID) | Greening Prey Lang Project | • Natural resource protection<br>• Improving community livelihoods<br>• Community capacity building | 2019-2023 |
| 04 | Ministry of Environment | Integrated Natural Resource Management (INRM) Project | • Natural resource protection and restoration<br>• Improving community livelihoods<br>• Training for promoting natural | 2023-2025 |